គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៥

ជូនចំពោះ ឯកឧត្តម Volker Türk
ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)
វិមានប្រជាជាតិ (Palais des Nations)
CH-1211 ហ្សឺណែវ ១០ ប្រទេសស្វីស

**កម្មវត្ថុ៖ ញត្តិបន្ទាន់ពាក់ព័ន្ធនឹងការប្រើប្រាស់សំឡេងរំខាន ដែលជាទម្រង់នៃការបំភិតបំភ័យ និងយាយីផ្លូវចិត្ត នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ពីសំណាក់កងទ័ពថៃ**

*ឯកឧត្តមជាទីគោរពរាប់អាន*

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក.) មានកិត្តិយសសូមគោរពជម្រាប ឯកឧត្តម អំពីការរំលោភ សិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ពាក់ព័ន្ធនឹងការប្រើប្រាស់សំឡេងរំខាន ដែលជាទម្រង់មួយនៃការបំភិតបំភ័យ និងយាយីផ្លូវចិត្ត នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ពីសំណាក់កងទ័ពថៃ។

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៥ គ.ស.ម.ក. បានទទួលរបាយការណ៍ពីអាជ្ញាធរមូលដ្ឋាន និងប្រជាជនរស់នៅក្នុងភូមិព្រៃចាន់ និងភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដោយបានអះអាងថា កងយោធា ថៃបានចាក់សំឡេងខ្មោចលងតាមរយៈឧបករណ៍បំពងសំឡេងដែលឮខ្លាំងៗ ចាប់ពីម៉ោង ១០ និង ៤៤ នាទី រសៀល រហូតដល់ម៉ោង ១២ និង ៤ នាទី កណ្តាលអាធ្រាត្រ និងបានបន្តចាក់សំឡេងរំខានជាសំឡេងយន្តហោះ ពីម៉ោង ៣ និង ២២ នាទី រហូតដល់ម៉ោង ៣ និង ៥៣ នាទី ទាបភ្លឺ ដោយមានគោលបំណងរំខាននិងបំភ័យប្រជាជនកម្ពុជា ដែលរស់នៅក្នុងសហគមន៍ក្បែរៗនោះ។ សំឡេងទាំងនេះ ត្រូវបានចាត់ទុកជាសំឡេងខ្លាំងនិងមានកម្រិតខ្ពស់ ក្នុងរយៈពេលយូរបានបង្កជាការរំខានដល់ការទទួលទានដំណេក ធ្វើឱ្យថប់អារម្មណ៍ និងបង្កឱ្យមានការមិនសុខស្រួលផ្លូវកាយដល់ប្រជាជនរស់នៅក្នុងតំបន់នោះ រួមទាំងស្ត្រី កុមារ ចាស់ជរា ជនមានពិការភាព និងអ្នកជំងឺ។ សកម្មភាពបែបវិទ្ធង្សនា និងបង្កហេតុទាំងនេះ មិនត្រឹមតែបង្កគ្រោះថ្នាក់ដល់ផ្លូវកាយនិងផ្លូវចិត្តរបស់ប្រជាជនកម្ពុជានោះទេ ថែមទាំងជាការគំរាមកំហែង និងបង្កើនភាពតានតឹងរវាងប្រទេសទាំងពីរទៀតផង។ សកម្មភាពទាំងនេះ មិនគួរមាន

ក្នុងសង្គមដែលមានអរិយធម៌ និងផ្ទុយទាំងស្រុងទៅនឹងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ដែលប្រកាន់ខ្ជាប់សន្តិភាព សិទ្ធិមនុស្ស និងការគោរពអធិបតេយ្យភាពគ្នាទៅវិញទៅមកក្នុងចំណោមប្រជាជាតិទាំងអស់។

សកម្មភាពខាងលើ គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរនូវស្មារតីកិច្ចព្រមព្រៀងស្តីពីបទឈប់បាញ់រវាងកម្ពុជានិងថៃ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ គោលការណ៍ព្រមព្រៀង ១៣ចំណុច នៃកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការកិច្ចការព្រំដែនទូទៅរវាងកម្ពុជានិងថៃ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥ និងបណ្តាលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ រួមមាន៖

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
- កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ
- កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- អនុសញ្ញាស្តីពីសិទ្ធិកុមារ
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ
- អនុសញ្ញាស្តីពីសិទ្ធិជនមានពិការភាព
- អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ គ.ស.ម.ក. សូមគោរពស្នើសុំឯកឧត្តម៖

១. **ផ្តួចផ្តើមការស៊ើបអង្កេតជាបន្ទាន់** អំពីការប្រើប្រាស់សំឡេងរំខាន ដោយកងទ័ពថៃ នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងធានាឱ្យមានការទទួលខុសត្រូវចំពោះការរំលោភបំពានច្បាប់សិទ្ធិមនុស្សនេះ។

២. **អំពាវនាវឱ្យបញ្ឈប់គ្រប់សកម្មភាព** ដែលគំរាមកំហែងផ្លូវចិត្តរបស់ប្រជាជនកម្ពុជា ជាពិសេសការប្រើប្រាស់សំឡេងរំខាននៅពេលយប់អធ្រាត្រ។

៣. **ធានាការការពារនិងការផ្តល់ជំនួយវេជ្ជសាស្ត្រនិងផ្លូវចិត្តចាំបាច់ផ្សេងៗ** ដល់ជនរងគ្រោះ រួមទាំងស្ត្រី កុមារ និងមនុស្សចាស់។

៤. **លើកទឹកចិត្តក្នុងការពង្រឹងកិច្ចសន្ទនាតាមព្រំដែនរវាងកម្ពុជានិងថៃ** ដើម្បីទប់ស្កាត់ការកើតឡើងវិញនូវភាពតានតឹង និងប្រកាន់ខ្ជាប់ការគោរពតាមស្មារតីកិច្ចព្រមព្រៀងស្តីពីបទឈប់បាញ់រវាងកម្ពុជានិងថៃ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ គោលការណ៍ព្រមព្រៀង ១៣ចំណុចនៃកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការកិច្ចការព្រំដែនទូទៅរវាងកម្ពុជានិងថៃ។

ជាមួយគ្នានេះ គ.ស.ម.ក. សូមគោរពអញ្ជើញ ឯកឧត្តម ចុះមកសង្កេតការណ៍ដោយផ្ទាល់ឱ្យបានឆាប់រហ័សបំផុតនៅតំបន់ព្រំដែនកម្ពុជា-ថៃ ដែលត្រូវបានរាយការណ៍អំពីការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ។ គ.ស.ម.ក. នឹងធានារ៉ាប់រងរាល់ការចំណាយ និងសម្របសម្រួលជាមួយនឹងអាជ្ញាធរពាក់ព័ន្ធទាំងអស់។

បេសកកម្មនេះ នឹងអនុញ្ញាតឱ្យ OHCHR ចុះសង្កេតការណ៍ដោយផ្ទាល់ អំពីស្ថានភាពនៅក្នុងតំបន់នោះ និងចូលរួមក្នុងការការពារសិទ្ធិមនុស្សនិងគោលការណ៍មនុស្សធម៌នៅនឹងកន្លែង។

គ.ស.ម.ក. សូមគូសបញ្ជាក់ថា សកម្មភាពគំរាមកំហែង ការឃាយី ឬការប្រព្រឹត្តបែបឃោរឃៅអមនុស្សធម៌ និងបន្ទាបបន្ថោក ចំពោះប្រជាជនកម្ពុជា គឺមិនអាចទទួលយកបានឡើយ ទោះស្ថិតក្រោមកាលៈទេសៈណាក៏ដោយ។

ប្រទេសកម្ពុជា នៅតែប្រកាន់ខ្ជាប់ដោយឥតងាករេចំពោះសិទ្ធិមនុស្ស អធិបតេយ្យភាព និងសន្តិភាព ស្របតាមច្បាប់អន្តរជាតិ។ ប៉ុន្តែសកម្មភាពដោយបំពាននិងឃាយីមកលើប្រជាជន គឺមិនអាចលើកលែងឱ្យបានឡើយ។

គ.ស.ម.ក. នៅតែប្តេជ្ញាចិត្ត ក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងឯកឧត្តម ព្រមទាំងសហការីឯកឧត្តម ក្នុងការដោះស្រាយបញ្ហា និងការពារសិទ្ធិមនុស្សរបស់ប្រជាជនស្លូតត្រង់រស់នៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ។

សូម ឯកឧត្តម ទទួលយកនូវការគោរពរាប់អានពីខ្ញុំ។

**ដោយក្តីគោរព**

**កែវ រ៉េមី**
**ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (CHRC)**
**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**
**អ៊ីម៉ែល៖** info@chrc.gov.kh
**លេខទំនាក់ទំនង៖** +៨៥៥ ៧៧ ៦២២ ៩៦៦ ឬ +៨៥៥ ៩៨ ៦២៣ ២៨៦